# ឯកសារសង្ខេបអំពីដៃគូអនុវត្តយុទ្ធសាស្ត្រ
# ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងពិការភាព

## សង្ខេបគម្រោង

គម្រោងពង្រឹងសេវាប្រកបដោយបរិយាបន្នសម្រាប់ជនជាតិដើមភាគតិចនេះ មានគោលបំណងពង្រឹងសំឡេង និងការចូលរួមរបស់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព ពង្រឹងការផ្តល់សេវាដល់ជនមានពិការភាព និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅថ្នាក់ក្រោមជាតិ ព្រមទាំងធានាបាននូវគោលនយោបាយឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគាត់។ អង្គការឃែរអន្តរជាតិប្រចាំនៅកម្ពុជា អនុវត្តវិធីសាស្ត្រភ្លោះ ដើម្បីពង្រឹងបរិយាបន្នពិការភាព និងស្របតាមក្របខ័ណ្ឌប្រកបដោយការគោរព[1] សម្រាប់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

## លទ្ធផលរំពឹងទុករបស់គម្រោង

- សហគមន៍ជនជាតិដើមភាគតិច ជនមានពិការភាព និង អង្គការក្នុងស្រុកមានការយល់ដឹងកាន់តែច្បាស់អំពីឫសគល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបង្កើនទំនុកចិត្តលើសិទ្ធិរបស់ខ្លួនដើម្បីជៀសផុតពីអំពើហឹង្សា។
- បង្កើនការយល់ដឹងអំពីសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ សេវាគាំទ្រ និងបង្កភាពងាយស្រួលក្នុងការទទួលបានសេវាដល់យុវជន ក្រុមងាយរងគ្រោះ ជនមានពិការភាព និងសហគមន៍ជនជាតិដើមភាគតិច។
- ការផ្លាស់ប្តូរនូវអាកប្បកិរិយាអវិជ្ជមាន ជំនឿ និងបទដ្ឋានសង្គមទៅកាន់យេនឌ័រ និងជនមានពិការភាព ក៏ដូចជាការលើកកម្ពស់ការផ្តល់សេវាផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងចំណោមសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ។
- ពង្រឹងការឆ្លើយតបរបស់ស្ថាប័នចំពោះជនរងគ្រោះដោយអំពើអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលភស្តុតាង ការស្វែងរកការគាំទ្រមតិគោលនយោបាយ ការពង្រឹងប្រព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (រួមមាន ការកសាងសមត្ថភាព ការសម្របសម្រួល ការត្រួតពិនិត្យ និងការវាយតម្លៃ) និងការហ្វឹកហ្វឺន និងបណ្តុះបណ្តាល។

RESPECT[1]: Relationship skills strengthened, Empowerment of women, Services ensured, Poverty reduced, Environments made safe, Child and adolescent abuse prevented, Transformed attitudes, beliefs, and norms

ACCESS 2
Sustainable quality services for all

Australian Aid

| សកម្មភាពសំខាន់ៗ |
|---|
| • កិច្ចសន្ទនានៅក្នុងសហគមន៍ទៅតាមស្រុកគោលដៅនីមួយៗអាចប្រើប្រាស់ ឧបករណ៍វិភាគសង្គម និងសកម្មភាពដើម្បីជំរុញដំណើរការស្វែងរក និងការឆ្លុះបញ្ចាំងដល់សកម្មភាពបុគ្គល និងសហគមន៍ ដែលគាំទ្របន្ថែមដល់សមភាពយេនឌ័រ និងបទដ្ឋានសង្គមផ្សេងទៀត។<br>• ផ្តល់នូវសកម្មភាពជម្រុញការផ្លាស់ប្តូរឥរិយាបថ ដែលរួមមានការគាំទ្រពីអ្នកមានវ័យប្រហាក់ប្រហែលគ្នា(ជនជាតិដើមភាគតិច) និងក្រុមបង្ការ ក៏ដូចជា បុគ្គលគំរូក្នុងសហគមន៍ ដែលលើកកម្ពស់ភាពវិជ្ជមាននៃភាពជាបុរស និងគាំទ្របទដ្ឋានសង្គមវិជ្ជមាននៃសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។<br>• ពង្រឹងសមត្ថភាពបច្ចេកទេស ទៅដល់អង្គការតំណាងជនមានពិការភាព ដែលធ្វើការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្តល់ព័ត៌មានអំពីសេវា តាមរយៈសកម្មភាពគាំទ្រផ្លូវចិត្តដល់ស្រ្តីមានពិការភាព។<br>• ពង្រឹងសមត្ថភាពក្រុមការងារក្នុងការឆ្លើយតបទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ (ខេត្ត និងស្រុក) ស្តីពីបរិយាបន្នពិការភាព។<br>• ធ្វើការវាយតម្លៃពិការភាពទៅលើសេវាឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលនឹងត្រូវអនុវត្តប្រកបដោយបរិយាបន្នពិការភាព ដោយមានការចូលរួមពីអ្នកជំនាញបច្ចេកទេសក្នុងដំណាក់កាលរចនា អនុវត្ត និងវិភាគ។<br>• ធ្វើការស្រាវជ្រាវទៅលើ បទដ្ឋានសង្គមបិតាធិបតេយ្យនៅក្នុងសហគមន៍ជនជាតិដើមភាគតិច អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូរយុទ្ធសាស្រ្តកម្មវិធី ACCESS 2 និងរៀបចំដំណើរទស្សនកិច្ចទៅកាន់កន្លែងផ្តល់សេវាចម្រុះខេត្តកំពង់ចាម ដែលជាបរិបទគម្រូមួយសម្រាប់ការអនុវត្តនៅខេត្តរតនគិរី។ |
| **អ្នកទទួលផល** |
| • **ក្រុមគោលដៅផ្ទាល់៖** សហគមន៍ជនជាតិដើមភាគតិច ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ស្រ្តីជនជាតិដើមភាគតិច ស្រ្តី និងកុមារមានពិការភាព) មនុស្សវ័យចំណាស់ដែលចូលរួមកិច្ចសន្ទនាសហគមន៍ និងលើកកម្ពស់ការយល់ដឹង ដៃគូអនុវត្តគម្រោង អ្នកចូលរួមគម្រោងឧបករណ៍វិភាគសង្គម និងអ្នកចូលរួមសកម្មភាពគម្រោង (បុរសជាជនជាតិដើមភាគតិច កុមារានិងមនុស្សវ័យចំណាស់នៅក្នុងភូមិ) អ្នកផ្តល់សេវាផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងពិការភាព មណ្ឌលសុខភាព អាជ្ញាធរមូលដ្ឋាន និងដៃគូអង្គការសង្គមស៊ីវិល។<br>• **ក្រុមគោលដៅប្រយោល៖** សហគមន៍ជនជាតិដើមភាគតិចនៅក្នុងស្រុកគោលដៅ សមាជិកគ្រួសាររបស់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសមាជិកគ្រួសាររបស់ជនមានពិការភាព។ |

| **តំបន់គោលដៅ** | |
|---|---|
| ខេត្តរតនគិរីៈ ស្រុកចំនួន៩ រួមមាន ស្រុកអណ្ដូងមាស ក្រុងបានលុង ស្រុកបរកែវ ស្រុកកូនមុំ ស្រុកលំផាត់ ស្រុកអូរជុំ ស្រុកអូរយ៉ាដាវ ស្រុកតាវែង និង ស្រុកវើនសៃ។ | |
| **ដៃគូអនុវត្តគម្រោង** | |
| ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល មន្ទីរកិច្ចការនារី អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន (PAfID) និងដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួនពីររួមមាន អង្គការថែរក្សាភាសាជនជាតិដើមភាគតិច (CIPL) និងអង្គការសមាគមខ្មែរលើ (HA)។ | |
| **រយៈពេលអនុវត្តគម្រោង** | |
| ខែមករា ឆ្នាំ២០២៤ ដល់ ខែមិថុនា ឆ្នាំ២០២៨ | |
| **ព័ត៌មានទំនាក់ទំនង** | |
| អង្គការ CARE Cambodia<br>លោកស្រី នៅ សុវត្ថា<br>នាយិកាប្រចាំប្រទេស<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៧២៥ ៧២១<br>អ៊ីម៉ែល៖ sovattha.neou@careint.org | កម្មវិធី ACCESS 2<br>លោកស្រី ប៊ូ មករា<br>ប្រធានផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៦៩៤ ៩៩៤<br>អ៊ីម៉ែល៖ makara.bou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤